# កិច្ចសម្ភាសរបស់ ម៉ូវ សុភ័ស

**កៈ អ្នកសម្ភាសឈ្មោះ គង់ សីហា** **ខៈ អ្នកដែលត្រូវសម្ភាសឈ្មោះ ម៉ូវ សុភ័ស**

កៈ បាទអ៊ំរ...ខ្ញុំពិតជាថ្លែងអំណរគុណខ្លាំងមែនទែនដល់អ្នកមីងដែលបានផ្ដល់ឧកាសដើម្បីឲខ្ញុំបានមានពេលវេលានេះបានមកសម្ភាសន៍អ្នកមីង អំពីជីវប្រវត្តិថាតើអ្នកមីងបានឆ្លងកាត់អ្វីខ្លះ? ហើយនឹងភាពសប្បាយយ៉ាងណាខ្លះ? អញ្ចឹងណាអ្នកមីង ហើយជាពិសេសមិនដឹងថាទាំងអស់នេះជា ពរជ័យមួយសំរាប់អ្នកមីងនឹងក្រុមគ្រួសារអ្នកមីងនៅថ្ងៃអនាគតដើម្បីឯកសារនេះទុកឲកូនចៅអ្នកមីងដើម្បីគាត់បានស្ដាប់ដឹងថាតើជីវប្រវត្តិឪពុកម្ដាយយ៉ាងមិចដែរ?ខ្ញុំដឹងថាពេលខ្លះកូនគឺអ៊ំរ....អ្នកមីងមិនសូវបានប្រាប់អំពីអ្វីជាច្រើនដល់កូនទេនឹងហើយដោយសារកូនខ្លះក៏អត់សូវដឹង អត់ចង់ដឹងអំពីឪពុកម្ដាយច្រើនដែរ អញ្ចឹងហើយបានជា ប្រូក្រាមមួយនេះគឺយើងចង់ដឹងចង់សម្ភាសន៍ទាំងអស់នេះដើម្បីឲអ្នកមីងបានប្រាប់ទៅ ហើយដើម្បីអនាគតកូនចៅនៅនឹកអ្នកមីង ឬ មួយក៏គេចង់ស្ដាប់គេអាចចូលស្ដាប់បាន អញ្ចឹងហាណា...បាទហើយការធ្វើសម្ភាសន៍នេះធ្វើឡើងដោយសាលាសកលវិទ្យាល័យមួយនៅសហរដ្ឋអាមេរិចដែលមានឈ្មោះថា BYU ហើយអញ្ចឹងសំឡេងរបស់អ្នកមីងនឹងដាក់ចូលទៅក្នុងនឹងផងដែរដើម្បីរក្សាទុកជារៀងរហូត  បាទហើយនៅស្រុកផ្សេងគឺយើងមានធ្វើកម្មវិធីហ្នឹងហើយនៅតែស្រុកខ្មែរមិនទាន់មានទេប៉ុន្តែឥឡូវយើងនឹងធ្វើកម្មវិធីនឹងដើម្បីជួយដល់ប្រជាជនខ្មែរយើងដើម្បីគាត់អាចមានអ៊ំរ....ជាជីវប្រវត្តិនិងពង្សាវតារបស់គាត់តែម្ដង បាទ!ហើយសំរាប់ខ្ញុំ ខ្ញុំឈ្មោះថា គង់ សីហា ខ្ញុំជាអ្នកសម្ភាសន៍អ្នកមីងនៅថ្ងៃហ្នឹង ថ្ងៃទី៥ ខែ៩ ឆ្នាំ២០១៦ នៅផ្ទះបងពិសីនៅកំពុងចាមអ៊ំរ....អ្នកមីង អ្នកមីងជួយប្រាប់ឈ្មោះទាំងឈ្មោះពេញរបស់អ្នកមីងឈ្មោះអីដែរ?

ខៈ ខ្ញុំឈ្មោះ ម៉ូវ សុភ័ស

កៈ ម៉ូវ សុភ័ស

ខៈ ចាស

កៈ ហើយអ្នកមីងមានឈ្មោះហៅក្រៅទេ?

ខ៖ អត់

ក៖ អត់មានទេ

ខ៖ ចាស

ក៖ ហ្នឹងហើ...ហើយអ័រ...អ្នកមីងអាចជួយប្រាប់ទីលំនៅផ្ទះអ្នកមីងនៅម្ដុំណាដែរ?

ខ៖ ខ្ញុំនៅ ភូមិអំពិលធំ ឃុំខ្វិតធំ ស្រុកព្រៃឈរ ខេត្តកំពុងចាម

ក៖ ខេត្តកំពុងចាមណ!...អ្នកមីងណ! បាទ!ប៉ុន្តែឥឡូវនេះអ្នកមីងមកគេងផ្ទះបងស្រី ពិសី នីម្ដុំអឹម...វត្តភ្នំ... ភ្នំប្រុសភ្នំស្រី

ខ៖ ចាស

ក៖ បា...ហើយអ័រ...អញ្ចឹងអ័រ...អ្នកមីងមានអ័រ...ថ្ងៃខែឆ្នាំមកំណើតមីងកើតនៅខែថ្ងៃណាដែរ?

ខ៖ ញុំមកើតនៅ...ថ្ងៃញុំមអត់ចាំហេញុំមកើតនៅឆ្នាំ១៩៧៤

ក៖ បូន...ហើយអ័រ...អ្នកមីងកើតនៅណាដែរ?

ខ៖ ខ្ញុំកើតនៅភូមិ អំពិលធំហ្នឹង

ក៖ អ...អញ្ចឹងអ្នកមីងកើត...

ខ៖ ចាស

ក៖ រស់នៅទីហ្នឹងរហូត?

ខ៖ ចាស...ចាស

ក៖ ហើយអ័រ...អញ្ចឹងភាគច្រើនសំរាប់ជនជាតិខ្មែរយើង យើងច្រើនប្រើឆ្នាំសត្វ មែនទេអ្នកមីង?

ខ៖ ចាស

ក៖ អ្នកមីងសត្វអីគេដែល?

ខ៖ ខ្ញុំសត្វខ្លា

កៈ ខ្លា! អូ!ខ្លាំងផងអញ្ចឹង

ខៈ សើច

កៈ បា... ហើយអ័រ...អញ្ចឹងអ្នកមីងអ័រ...អ្នកមីងមានបងប្អូនប៉ុន្មាននាក់ដែលអ្នកមីង?

ខៈ ខ្ញុំមានបងប្អូន៤នាក់

កៈ ៤នាក់

ខៈ ចាស

កៈ អញ្ចឹងមានឈ្មោះអីដែលអ្នកមីង?

ខៈ អ័រ...ទី១ឈ្មោះ ម៉ូវ សាត

កៈ ម៉ូវ សាត! បើឥឡូវគាត់អាយុប៉ុន្មានហើយ?

ខៈ គាត់អាយុ៥០ឆ្នាំហើយ

កៈ ហ្នឹង?

ខៈ ចាស

កៈ តោះទី២

ខៈ ទី២ឈ្មោះ ម៉ូវ សន

កៈ ម៉ូវ សន

ខៈ តែគាត់ស្លាប់បាត់ហើយ

កៈ ហូ!

ខៈ ចាស

កៈ ឥឡូវអាយុប៉ុន្មានហើយអ្នកមីង?

ខៈ ប្រហែល ៤៥ បើគិត

កៈ ៤៥? បា!

ខ៖ ចាស!

ក៖ ចុះបន្ទាប់មកទៀត?

ខ៖ ខ្ញុំសែ...ខ្ញុំសែប៉ុន្មានឪអាដា?៤១

ក៖ ៤១?

ខ៖ ចាស

ក៖ បា! ហើយបន្ទាប់មកទៀត?

ខ៖ មកទៀតឈ្មោះ ម៉ូវ សុភា ៣៧ឆ្នាំ

ក៖ ៣៧ឆ្នាំ! ហើយចុះសំរាប់រាល់ថ្ងៃពួកគាត់នៅជាមួយហ្នឹងទាំងអស់គ្នានៅជាមួយគ្នា ក៏គាត់បែកគ្រួសារហើយ?

ខ៖ អ័រ...បងប្រុសខ្ញុំបងគេបំផុតគាត់នៅភ្នំពេញ

ក៖ បាត!

ខ៖ ដល់បងទី២គាត់ស្លាប់ហើយដល់បន្ទាប់មកខ្ញុំបន្ទាប់មកប្អូនខ្ញុំគាត់នៅភូមិអំពិលធំនៅផ្ទះជិតខ្ញុំដែរ ចាស...

ក៖ បាទអ្នកមីង ហើយអ័រ...អញ្ចឹងសំរាប់អ្នកមីង អ្នកមីងបានអ័រ...ឆ្លងកាត់អាពាហ៍ពិពាហ៍ដែរមែនទេអ្នកមីង?

ខ៖ ចាស! ខ្ញុំធ្លាប់បានឆ្លងកាត់រៀបអាពាហ៍ពិពាហ៍

ក៖ កាលរៀបអាពាហ៍ពិពាហ៍អ្នកមីងហ្នឹង នៅឆ្នាំណាដែរ?

ខ៖ នៅឆ្នាំ ១៩៨៨

ក៖ ៨៨...ជាមួយលោកពូហ្នឹងមែនទេ?

ខ៖ ហ្នឹងហើយ

ក៖ ហ្នឹងហើយ ហើយអ័រ...អ្នកមីងកាលរៀបអាពាហ៍ពិពាហ៍ហ្នឹងអ្នកមីងរៀបនៅម្តុំណាដែរ?

ខ៖ នៅភូមិ អំពិលធំ

កៈ ភូមិអំពិលធំហ្នឹងតែម្តង

ខៈ ចាស ចាស

កៈ ហើយពេលអ្នកមីងរៀបអាពាហ៍ពិពាហ៍ហ្នឹងឪពុកម្តាយដឹងលឺដែរទេ?

ខៈ ចាស! គាត់ដឹងដែរតាស

កៈ គាត់ដឹងដែរ

ខៈ ចាស

កៈ គាត់អ្នករៀបចំអោយមែនទេ?

ខៈ ចាស គាត់អ្នករៀបចំអោយ

កៈ ហើយនៅស្រុកខ្មែរយើងភាគច្រើនគឺយើងមានហៅថា បណ្ណាការតើអ័រ...លោកពូបានផ្តល់បណ្ណាការ លោកពូប៉ុន្មានដែរ  ហូ!អ្នកមីងប៉ុន្មានដែរ?

ខៈ កាលហ្នឹងបាន៥ជី

កៈ ៥ជី

ខៈ ចាស

កៈ ច្រើនដែរអញ្ចឹង

ខៈ ច្រើនដែល (សើច)

កៈ ៥ជី

ខៈ ចាស

កៈ បន្ទាប់មកគាត់មានអោយអីទៀតដែរ?

ខៈ អត់ផង

កៈ អត់មានទេ បាទ!

ខៈ ចាស

កៈ ហើយអ័រ...អ្នកមីងខ្ញុំចង់សួរសំនួរមួយហើយសំនួរនេះគឺជាសំនួរពិសេសមួយដែរកូនចៅអ្នកមីងនឹងអាចចង់ដឹងរឿងហ្នឹង អញ្ចឹងបានន័យថាពេលអ្នកមីងរៀបការជាមួយលោកពូឆ្លងកាត់ដោយការរៀបការ អញ្ចឹងធ្វើយ៉ាងណាបានជាអ្នកមីងសំរាចចិត្តថាអ្នកមីងចង់រៀបការជាមួយលោកពូ? ហើយអ្នកមីងគិតថាជួបលោកពូនៅកន្លែងណា?បានជាអ្នកមីងគិតថា ហ្ស!ស្រលាញ់លោកពូចូលចិត្ត

លោកពូអញ្ចឹងអីទៅណា

ខៈ ចាស

កៈ អាចប្រាប់ប៉ុណ្ណឹងបានទេ?

ខៈ អ័រ...កន្លែងហ្នឹងខ្ញុំដោយសារឪពុកម្ដាយគាត់អ្នករៀបចំទុកដាក់ដោយខ្ញុំអត់មានបានប្រកែកអីជាមួយគាត់ទេ

កៈ ហ្ស!

ខៈ ចាស

កៈ ចុះភាគច្រើនឪពុកម្ដាយជាអ្នកផ្សំផ្គុំ?

ខៈ ចាស គាត់ជាអ្នករៀបចំ ពិព្រោះអីក្មេងៗជំនាន់ខ្ញុំហ្នឹងស្រាចតែ

ឪពុកម្ដាយជាអ្នកទុកដាក់ទេ

កៈ ហ្ស! បើសិនជាឧទាហរណ៍ថាពេលពួកគាត់ទុកដាក់ទៅអ្នកមីងអត់ពេញចិត្តមិចវិញអញ្ចឹង?

ខៈ អត់អីទេ តែមុននឹងគាត់រៀបចំគាត់សួរខ្ញុំដែរ

កៈ ហ្ស! អញ្ចឹងអ្នកមីងអត់អីទេ

ខៈ ចាស អត់អីទេហ្នឹងហើយខ្ញុំតាមគាត់ដែរ

កៈ បា...

ខៈ ចាស

កៈ ហើយអ្នកមីងប៉ុន្មានឆ្នាំបានអ្នកមីងបានរៀបការពេលគាត់ចូលស្ដីអីអស់ហ្នឹង?

២: អ័រ...ស្ដីបានជាប្រហែលកន្លះឆ្នាំ

កៈ កន្លះឆ្នាំ

ខៈ ចាស

កៈ ហើយនៅក្នុងពេលកន្លះឆ្នាំហ្នឹងអ្នកមីងមានអ័រ...ដូចថាជួបគ្នា ឬ ទៅដើរលេងណាខ្លះ?

ខៈ អត់ដែរសោះ

កៈ អត់ដែរសោះ?

ខៈ អត់ដែរសោះ ចាស

កៈ អត់ដែរជួបគ្នាទៀត?

ខៈ អត់ដែរជួបសោះ

កៈ អញ្ចឹងបានន័យថាដល់ថ្ងៃដែរអ្នកមីងចូលរោងការគឺចូលតែម្ដង?

ខៈ ចាស ហ្នឹងហើយចូលតែម្ដងអត់ដែលបានជួបគ្នា អត់ដែរជួបមុខគ្នាសោះ

កៈ អញ្ចឹង អត់ដឹងថាកូនកំលោះនឹងមុខយ៉ាងមិចទេណា! តែដឹងតាគេចូលស្ដីដណ្ដឹងយើង?

ខៈ ចាស (សើច)

កៈ ហើយដល់ពេលអញ្ចឹងពេលអ្នកមីងបានរៀបអាពាហ៍ពិពាហ៍ហើយបន្ទាប់រហូតមកដល់ឥឡូវហ្នឹងអ្នកមីងមានកូនប៉ុន្មាននាក់ដែរ?

ខៈ ញ៉ុមមានកូន៣នាក់

កៈ ៣នាក់?

ខៈ ចាស

កៈ ទី១មានឈ្មោះអីដែលអ្នកមីង?

ខៈ ទីមួយឈ្មោះ រ៉េតមុនី

កៈ បាទ ទី២?

ខៈ ទី២ឈ្មោះ រ៉េត សុនីម

កៈ ហ្វ! រ៉េត មុនី នឹងអាយុប៉ុន្មានហើយដែរអ្នកមីង?

ខៈ អាយុសព្វថ្ងៃ១៧ឆ្នាំហើយដែរ

កៈ ហើយចុះរ៉េត....ទី២?

ខៈ ទី២ឈ្មោះ រ៉េត សុនីម

កៈ រ៉េត សុនីមអាយុប៉ុន្មានហើយ?

ខៈ ១២ឆ្នាំ

កៈ ១២ឆ្នាំ ហើយចុះបន្ទាប់ទៀត?

ខៈ រ៉េត ហាន់ណាអាយុ៥ឆ្នាំ

កៈ ៥ឆ្នាំ! ពៅ...បាទហើយសព្វថ្ងៃពួកគេប្រកបមុខរបរ ឬ ពួកគាត់នៅតែរៀនទេអ្នកមីង?

ខៈ ពួកគាត់នៅសិក្សា

កៈ នៅសិក្សានៅឡើយ

ខៈ ចាស

កៈ ហើយពួកគាត់រៀននៅណាវិញអ្នកមីង?

ខៈ អ័រ...មុនីគាត់រៀននៅសាលាអនុវិទ្យាល័យ ល្វា

កៈ ល្វា!

ខៈ ចាស អ័រ...សុនីមគាត់រៀននៅសាលា អំពិលធំ

កៈ អំពិលធំ បាទ

ខៈ ចាស

កៈ ចុះប្អូនតូច?

ខ៖ អូនតូចអត់ទាន់ទេនៅផ្ទះ

ក៖ អត់ទាន់ទេចូលរៀនអង់គ្លេសទៅក្មួយ

ខ៖ ចាស (សើច)

ក៖ អ័រ...អញ្ចឹងអ្នកមីងសំរាប់អ័រ...សំរាប់អ័រ...ឪពុកម្តាយអ្នកមីងវិញតើអ្នកមីងបានចងចាំអ្វីខ្លះអំពីពួកគាត់?

ខ៖ កាលរស់នៅជាមួយគាត់ហោ?

ក៖ ហ្នឹងហើយ

ខ៖ កាលរស់នៅជាមួយគាត់ញ៉ុមចងចាំបានពេលគាត់នាំទៅធ្វើស្រែអីអញ្ចឹងដែលញ៉ុមមានអនុស្សាវរីយជាមួយគាត់ ដូចជាមួយឪពុកខ្ញុំគាត់នាំខ្ញុំទៅកាប់អូសនៅព្រៃលើអី ក៏ខ្ញុំមានអនុស្សាវរីយជាមួយគាត់ជាច្រើនដល់ពេលឥឡូវគាត់ស្លាប់បាត់ ខ្ញុំនៅតែនឹកឃើញអនុស្សាវរីយជាមួយគាត់ គាត់នាំខ្ញុំតូចៗចឹងទៅកាប់អូស ជូនកាលបរទេះភ្លុកអីដែរ

ក៖ រទេះភ្លុកមិចទៅ?

ខ៖ រទេះភ្លុកតាមផ្លូវ រទេះភ្លុកហា!

ក៖ អ័រ...វាដូលមែន?

ខ៖ រទេះគោហា!

ក៖ អ័រ...វាដួលមែនអាហ្នឹង?

ខ៖ ចាស ពេលណាវាឡើងភ្លឺខ្ពស់ម្ខាងទាបម្ខាងវាក្រឡាប់ហា

ក៖ អូ!

ខ៖ ចាស ភ្លុកជួនកាលខ្ញុំនឹងប៉ះត្រូវនឹងអូសត្រូវនឹងអីរូតជួនកាលយប់អាត្រាតបានមកដល់ផ្ទះជាមួយឪពុកខ្ញុំហា

ក៖ បាទ

ខ៖ ចាស ហើយញ៉ុមធ្វើស្រែជាមួយគាត់ ញ៉ុមដាំបន្លែ ដូចជាដាំត្រសក់ ដាំស្ពៃអីបាន ញ៉ុមទៅលក់កាលប្រវត្តិញ៉ុមនៅជាមួយគាត់នឹងណា

ក៖ ហ្នឹងហើយ

ខ៖ ចាស

ក៖ មានអីទៀតទេអ្នកមីង?

ខ៖ ប៉ុណ្ណឹង

ក៖ ចុះសំរាប់ម្ដាយអ្នកមីងវិញតើអ្នកមីងមានបទពិសោធន៍អីខ្លះជាមួយនឹងម្ដាយ?

ខ៖ អ័រ...ចំនែកម្ដាយញ៉ុមដូចតែឪពុកញ៉ុមដែរ ប៉ុន្តែម្ដាយខ្ញុំគាត់អត់បានទៅព្រៃទៅបឹងអីជាមួយញ៉ុមទេបានតែជាមួយឪពុក...ចាស។

ក៖ ok...បាទហើយចុះឪពុកអ្នកមីងឈ្មោះអីដែរ?

ខ៖ ឪពុកញ៉ុមឈ្មោះ គឹម សុត

ក៖ គឹម សុត! ចុះម្ដាយវិញ?

ខ៖ ម្ដាយឈ្មោះ ចក់ រើន

ក៖ ចក់ រើន! ឪពុកអាយុប៉ុន្មានដែរអ្នកមីង?

ខ៖ ពុកខ្ញុំកាលគាត់ស្លាប់នឹងអាយុ៦០

ក៖ ៦០?មកដល់ឥឡូវអាយុប៉ុន្មានហើយ?

ខ៖ ប្រហែលជា ៦៣

ក៖ ៦៣? ៣ឆ្នាំមុនអញ្ចឹង?

ខ៖ ចាស

ក៖ ចុះ ម្ដាយអ្នកមីងវិញ?

ខ៖ ម្ដាយឈ្មោះ ចក់រើន

កះ ចក់ រើន! អាយុប៉ុន្មានហើយអ្នកមីង?

ខះ គាត់អាយុ៥៣...ហ្វ...៥៧ឆ្នាំ

កះ ៥៧! ចុះគាត់នៅរស់ ឬក៏...?

ខះ ចាស គាត់នៅរស់សព្វថ្ងៃ

កះ បាទ! ហើយពួកគាត់ទាំង២អ្នកមីងដឹងថាគាត់កើតនៅទីកន្លែងណាដែរទេ?

ខះ ពុកខ្ញុំហេ?

កះ បាទ

ខះ ពុកខ្ញុំគាត់កើតនៅ អំពិលធំដែរ

កះ អំពិលធំ! ចុះម្ដាយ?

ខះ ម្ដាយអញ្ចឹងដែរ

កះ ដូចគ្នា?

ខះ ចាស! ដូចគ្នាអត់មានទៅណាទេ...(សើច)

កះ ចាស់ គេហៅថា...

ខះ ចាស់ពីដើម ហា..

កះ ចាស់ពីដើម ហា...បាទ

ខះ អត់ហ៊ានដើរចោលស្រុកដើរចោលគុម្ពស្លឹកគ្រៃជីមួយដើមនឹងទេ

កះ អញ្ចឹង ហា!

ខះ ចាស

កះ បាទ! ហើយគាត់ដែររៀនភាសាបរទេសអីដែលទេអ្នកមីង?

ខះ អត់ទេ អត់ដែលបើម្ដាយខ្ញុំវិញគាត់អត់ដែររៀនភាសារខ្មែរយើងផង

កះ អញ្ចឹង?

ខ៖ អត់ដែររៀនទេ កាលជំនាន់នឹងចាស់ៗគាត់ថាកូនស្រីអត់អោយរៀនទេអោយនៅតែផ្ទះ បើពុកខ្ញុំគាត់មានការចេះដឹងខ្លះៗ ដោយសារគាត់បួសលោកហា! គាត់រៀននៅសាលាជាមួយលោកនៅវត្ត

ក៖ ហ្អឹងហើយ

ខ៖ ចាស

ក៖ ហើយអញ្ចឹងលោកពូអ្នកមីងដែលទៅប្រទេសខាងក្រៅអីទេ?

ខ៖ អត់ទេ អត់ដែលទៅទេចាស

ក៖ ចុះសំរាប់ខេត្តនៅក្នុងស្រុកខ្មែរយើងគាត់ដែលទៅខេត្តណាខ្លះអ្នកមីង?

ខ៖ បើពុកខ្ញុំពីដើមមកញ៉ុមនៅតូចៗប៉ុន ហាន់ណាប៉ុនអីនឹងគាត់មករត់...ស្អីទេនៀក? ធាក់កង់បីនៅកំពុងចាម!ឪពុកញ៉ុមហា! ម្តាយញ៉ុមគាត់អត់ដែលទៅណាទេគាត់នៅតែផ្ទះ

ក៖ នៅតែផ្ទះ?

ខ៖ ចាស

ក៖ អញ្ចឹង! លោកពូដែលទៅភ្នំពេញ?ដែលទៅសៀមរាប?ដែលទៅណាទេ?

ខ៖ ពុកញ៉ុមហា?អត់ដែលសោះ

ក៖ អត់ដែលសោះម៉ង?

ខ៖ ចាស

ក៖ ចុះអ្នកមីងអាចចាំអំពីជីដូនជីតារបស់អ្នកមីងទេ?

ខ៖ ជីដូនជីតានឹងមិចដែល?

ក៖ ឪពុកជីតាតួត...អ្នកមីង

ខ៖ ញ៉ុមចាំតែតា បើឪពុកឪពុកខ្ញុំគាត់ឈ្មោះតា ម៉ូវ

ក៖ ចុះយាយ?

ខ៖ យាយឈ្មោះយាយ អួន

ក៖ យាយ អ្ូន

ខ៖ ចាស

ក៖ ហើយកើតនៅណាដែល?

ខ៖ ញ៉ុមអត់ដឹងទេនៀក!

ក៖ អត់ដឹងទេ ណា!

ខ៖ ចាស ញ៉ុមអត់បានដឹងសោះ

ក៖ ហើយសំរាប់អ្នកមីង អ្នកមីងដែលទៅប្រទេសខាងក្រៅដែរ ឬ ទេ?

ខ៖ ញ៉ុមដែលទៅកាលទៅ វិហារបរិសុទ្ធ នៅហុងកុងហ្នឹង

ក៖ ទៅហុងកុង! អញ្ចឹងទៅជាម្នាក់éង ឬ ទៅជាក្រុមគ្រួសារ?

ខ៖ ញ៉ុមទៅជាលក្ខណះគ្រួសារ

ក៖ គ្រួសារ! ហើយអ្នកមីងអ័រ...ពេលទៅហុងកុងហ្នឹងសប្បាយទេ?ដើរលេងណាខ្លះ?

ខ៖ សប្បាយដែលតាសកាលហ្នឹងដល់ពេលចប់ការងារ ២ ៣ ថ្ងៃនឹងទៅគេនាំដើរលេងផ្សារមួយល្ងាចដែរ ហ្នឹងហើយ!ចាស

ក៖ ហើយអ័រ...អ្នកមីងមានបទពិសោធន៍អីខ្លះពីហុងកុងហ្នឹង?

ខ៖ ញ៉ុមមានបទពិសោធន៍ដូចជា មើលទៅប្រទេសគេវាស្អាតហើយវាសប្បាយអញ្ចឹងហា! វាខុសពីស្រុកខ្មែរយើងហា!

ក៖ បាទ

ខ៖ ចាស

ក៖ ហើយសំរាប់អ្នកមីងវិញអ្នកមីងដែលរៀនពីមុនមកទេ?

ខ៖ ញ៉ុមធ្លាប់រៀនដែរ

ក៖ រៀនថ្នាក់ទីប៉ុន្មានដែរ?

ខ៖ ញ៉ុមកាលហ្នឹងរៀនថ្នាក់ទី៩ហ្នឹង! គេឌីប្លូមកាលហ្នឹងហា!

ក៖ បា...ហ្នឹងហើយ

ខ៖ ចាស

ក៖ អញ្ចឹងអ្នកមីងចេះអានអក្សរ?ចេះសរសេអក្សរទេ?

ខ៖ ញ៉ុមចេះអានចេះសរសេ

ក៖ ហ្នឹងហើយ! អ្នកមីងអញ្ចឹងឥឡូវញ៉ុមសុំសួរអំពីអ័រ...ជីវប្រវត្តិរបស់អ្នកមីងវិញតាំងពីតូចរហូតមកដល់អ្នកមីងធំដឹងក្ដីពីមុនរៀបការអ្នកមីងមានឆ្លងកាត់អ្វីខ្លះដែរ?

ខ៖ ញ៉ុមតាំងពីតូចមកដល់សម័យនឹងដូចគ្មានឆ្លងកាត់អីទេ ញ៉ុមរស់នៅធម្មតាហ្នឹង ចាស ហើយអត់ដែលជួបទុក្ខលំបាកអីទេតាំងពីនឹងមកនេះ

ក៖ អញ្ចឹង!

ខ៖ ធម្មតា ចាស

ក៖ អញ្ចឹងអ្នកមីងអ័រ...ពេលអ្នកមីងបានរៀនចប់ថ្នាក់ទី៩ អញ្ចឹងពេលអ្នកមីងរៀនចប់អ្នកមីងធ្វើអីគេដែលពេលចប់?

ខ៖ កាលនុះម្ដាយញ៉ុមឲទៅរៀនដេរ

ក៖ រៀនដេរ?

ខ៖ ចាស

ក៖ ដល់ពេល...ហេតុអីបានគាត់ឲអ្នកមីងទៅរៀនដេរ?

ខ៖ គាត់ថាកូនស្រីនៅផ្ទះត្រូវតែចេះដេរតិចតួចដើម្បីមានលុយទិញម្ហូបអីញ៉ាំអញ្ចឹង! ហើយគាត់ឲញ៉ុមទៅរៀនដេរកាលហ្នឹង

ក៖ អ័រ...ហើយអ្នកមីងចេះដេរ ចេះដេរម៉ូតខោអាវ ឬ ដេរធម្មតា?

ខ៖ ដេរធម្មតា

ក៖ អត់ម៉ូតខោអាវទេ?

ខ៖ ចាស អត់ចេះទេ

ក៖ ហើយអ្នកមីងរៀនហ្នឹង រៀនប៉ុន្មានឆ្នាំដែលកាលហ្នឹង?

ខ៖ ញ៉ុមកាលហ្នឹងរៀនបានប្រមាណ ២ទៅ៣ខែសោះហ្នឹង

ក៖ ហ្នឹងហើយ!

ខ៖ ចាស

ក៖ ហើយដល់ពេលបន្ទាប់ពីអ្នកមីងរៀនដេរហើយអ្នកមីងធ្វើអីទៀត?

ខ៖ ដល់ពេលខ្ញុំរៀនដេរចប់ខ្ញុំរៀបអាពាហ៍ពិពាហ៍ហ្នឹង!

ក៖ រៀបការជាមួយលោកពូ?

ខ៖ ចាស

ក៖ ដល់ពេលអ្នកមីងរៀបអាពាហ៍ពិពាហ៍ បន្ទាប់មកអ្នកមីងចាប់ផ្ដើមធ្វើអីគេបន្ទាប់ពីជីវិតរៀបអាពាហ៍ពិពាហ៍រួចហើយ?

ខ៖ បន្ទាប់ពីរៀបអាពាហ៍ពិពាហ៍ហើយមក ញ៉ុមដេរបានប៉ុន្មានឆ្នាំក៏ឈប់ទៅមានកូនមានចៅលែងបានដេរទៅ

ក៖ ចុះអ្នកមីងមានបានធ្វើអីទៀតទេបន្ទាប់ពីមានកូន?

ខ៖ រាល់ថ្ងៃហ្នឹងញ៉ុមអត់មានធ្វើអីសោះនៅតែផ្ទះមើលកូន

ក៖ មើលកូន!

ខ៖ ចាស

ក៖ អញ្ចឹងសំរាប់អ្នកមីងអត់ធ្វើអីសោះ អញ្ចឹងលោកពូបានធ្វើអីគេដែរ?

ខ៖ គាត់ធ្វើពេទ្យ

ក៖ ពេទ្យ! បាទ

ខ៖ ហ្នឹងហើយ!

កៈ អញ្ចឹងអ្នកមីងអ័រ...លោកពូគាត់មានអាយុប៉ុន្មានហើយ?

ខៈ ពូឌី ៨៣ឆ្នាំ

កៈ ៨៣...គាត់ឈ្មោះពេញឈ្មោះអីដែលអ្នកមីង?

ខៈ ឈ្មោះ កូវ វង្សឌី

កៈ កូវ វង្សឌី! បាទ

ខៈ ចាស

កៈ ហើយរាល់ថ្ងៃក្រុមគ្រួសាររបស់អ្នកមីងប្រកបអាជីវកម្មអីដែល ឬ មួយក៏យ៉ាងមិច?

ខៈ រាល់ថ្ងៃក្រុមគ្រួសារញ៉ុមប្រកបអាជីវកម្មគាត់ធ្វើពេទ្យហ្នឹង

កៈ ធ្វើពេទ្យ

ខៈ ចាស ហើយធ្វើស្រែតិចតួច

កៈ បាទ...ធ្វើស្រែតិចតួចអញ្ចឹងសំរាប់អ្នកមីងអ្នកមីងចេះធ្វើស្រែទេ?

ខៈ ចាសចេះដែលតាស

កៈ ហើយអ្នកមីងមានស្រែប៉ុន្មានហិចតាដែរ?

ខៈ ញ៉ុមមានដីប្រមាណកន្លះហាត់ហ្នឹង

កៈ កន្លះហាត់នឹងជាប៉ុន្មានម៉ែត្រ?

ខៈ កន្លះហាត់នឹង?....ប៉ុន្មានទេ?ញ៉ុមដឹងតែកន្លះហាត់មិនដឹងប៉ុន្មានទេ

កៈ ហើយពេលដែលភាគច្រើនអ្នកមីងធ្វើស្រែហ្នឹងខ្លួនឯង ឬ អ្នកមីងជួលដីហ្នឹងអោយគេ?

ខៈ ជួលដីអោយគេ

កៈ ជួលដីអោយគេ?

ខៈ ចាស ដោយសារញ៉ុមមានកូនញ៉េចញ៉ាចចឹងញ៉ុមជួលអោយគេទៅចាស

កៈ ហើយចុះពេលអង្ករអី អ្នកមីងទិញអង្ករមកហូបអញ្ចឹងទៅ?

ខ៖ ចាស ទិញអង្ករហូបដែលតាស

ក៖ អ័រ...កាលអ្នកមីងនៅរៀនអ្នកមីងរៀននៅសាលាណាដែរ?

ខ៖ ញ៉ុមរៀននៅ...មុនគេញ៉ុមចូលរៀនថ្នាក់ទី១នៅសាលាអំពិលធំ

ក៖ បាទ

ខ៖ ដល់ហើយឡើងថ្នាក់ទី៣ ញ៉ុមរៀននៅសាលា ពោធិក្រោម ដល់បន្ទាប់ហើយមកចូលសាលាគិលាស ចូលសាលាព្រៃទទឹង

ក៖ ហេតុអ្វីអ្នកមីងដូរសាលាច្រើនម្លេះ?

ខ៖ គេទៅតាមថ្នាក់ដល់ពេលថ្នាក់ទី១ ទី២ ទី៣ ចប់មួយសាលាអញ្ចឹងគេឲឡើងទៅសាលាមួយទៀត...ចាសដល់ពេលថ្នាក់ទី៥យើងប្រលង គិលាសហ្នឹងមកសាលាព្រៃទទឹង

ក៖ ហូ!

ខ៖ ហ្នឹងហើយ!

ក៖ ហើយអ្នកមីងសំរាប់កូនអ្នកមីង៣នាក់ហ្នឹងអ្នកមីងគិតថាពួកគេមានអត្តចរិកយ៉ាងមិចដែរ?

ខ៖ សំរាប់កូន៣នាក់ហ្នឹង សំរាប់ មុនីគេមានអត្តចរិកល្អ តែបើ សុខនីមរៀងក្រឡិចក្រឡុចខិលបន្តិច

ក៖ ហូ!

ខ៖ ហ្នឹងហើយ! ហាន់ណាក៏គេត្រឹមត្រូវដែរ ចាស

ក៖ អញ្ចឹងបានន័យថាពួកគេទាំង៣ មានអត្តចរិកខុសៗគ្នា?

ខ៖ ខុសៗហ្នឹងហើយ...(សើច)

ក៖ បាទ...អ័រហើយអ័រ...អញ្ចឹងដូចជាសំរាប់អ្នកមីងពេលអ្នកមីងតាំងពីអ្នកមីងតូចរហូតដល់ធំហ្នឹងហា អ្នកមីងដែលប៉ះចំពេលវេលាណាមួយដែលពិបាកបំផុតទេ?

ខ៖ អត់ធ្លាប់ អត់ដែរជួបសោះហើយ

កៈ ចុះអ្នកមីងដែរមានភាពឈឺចាប់អ៊ឹម...ម្ដងណាអីទេ?

ខៈ អត់ដែល

កៈ អត់ដែលម៉ង?

ខៈ អត់ដែលធ្លាប់សោះ

កៈ ហើយអ្នកមីងដែល...ដូចថាពីមុនរៀបការជាមួយលោកពូ អ្នកមីងដែលថាអ័រ...មានបុរសណាផ្សេងៗដែរគេចូលមកសួរអ្នកមីងអីដែរទេ?

ខៈ អត់ផង...ហ្ង!...ធ្លាប់ចូលសួរហ?មានដែលតាស

កៈ គេធ្លាប់ស្រលាញ់អីអញ្ចឹងណា

ខៈ ហ្នឹងហើយ!

កៈ មានច្រើនទេ?

ខៈ មានច្រើនតាស

កៈ មានច្រើន! អញ្ចឹង?

ខៈ តែក្មេងៗជំនាន់ហ្នឹងអត់ដូចជំនាន់ឥឡូវទេ

កៈ ជួយប្រាប់បន្តិចបានទេ?

ខៈ ក្មេងៗពីមុនទាល់តែម្ដាយអោយយកបានហ៊ានយកណា! មិនមែនដូចក្មេងៗឥឡូវទាល់តាវាស្រលាញ់គ្នាហើយបាននាំមកអោយឪពុកម្ដាយមើល មិនអញ្ចឹង? ក្មេងជំនាន់ញ៉ុមអត់អញ្ចឹងទេទោះបីគេស្រលាញ់ក៏ដោយគេចូលសួរក៏ដោយបើឪពុកម្ដាយអត់ពេញចិត្តគាត់អត់ថទេ

កៈ ហ្ង!

ខៈ ចាស អញ្ចឹង!

កៈ អញ្ចឹងបើសិនជាឧទាហរណ៍ថាអ្នកមីងស្រលាញ់នរណាម្នាក់ ហើយបន្ទាប់មកឪពុកម្ដាយអត់អោយអញ្ចឹងអ្នកមីងគិតយ៉ាងមិចវិញ?

ខ៖ អត់អីទេដល់ញុំមតាមគាត់

ក៖ តាមគាត់?

ខ៖ ចាស

ក៖ ហ្នឹងហើយ!...ហើយអ័រ...អញ្ចឹងនៅពេលដែរអ្នកមីងទៅសាលារៀនពេលនៅរៀនអ្នកមីងមានលុយគ្រប់គ្រាន់ទៅរៀនទេ?

ខ៖ អត់មានទេ កាលហ្នឹងពិបាកសូម្បីតែសៀវភៅ សំភារៈសរសេអីហ្នឹងអត់ដែលមានគ្រប់គ្រាន់ទេ តែញុំមចេះតែតស៊ូហើយកាលហ្នឹងព្រោះឪពុកម្តាយញុំមគាត់ជាអ្នកធ្វើស្រែចំការអញ្ចឹងគាត់តែងតែមានការខ្វះខាតហើយកាលហ្នឹង បងប្អូនញុំមរៀន៣នាក់ ដល់ពេលអញ្ចឹង កង់មួយឌុបគ្នា២នាក់ ដល់៣នាក់ម្នាក់ជិះកង់មួយម្នាក់ឯង

ក៖ បាទ

ខ៖ អញ្ចឹងបងញុំម២នាក់ហ្នឹងដូរគ្នាឌុបញុំមម្តងម្នាក់ញុំមអត់ចេះជិះកង់ទេកាលហ្នឹងហា

ក៖ បាទ

ខ៖ ចាស

ក៖ ហើយចុះយ៉ាងមិចទៀតដែរអ្នកមីង?

ខ៖ ប៉ុណ្ណឹង

ក៖ ប៉ុណ្ណឹង! បាទហើយដល់ពេលអ័រ...អញ្ចឹងភាគច្រើនអ័រ...ក្រុមអ័រ...អ្នកមីង អ្នកមីងដែលអ័រ...ធ្វើស្រែចំការទេ?

ខ៖ ញុំមធ្លាប់ធ្វើ

ក៖ ធ្លាប់ធ្វើណា!

ខ៖ ចាស

ក៖ ហើយអ្នកមីងដែរធ្លាប់រកស៊ីអីទេ?

ខ៖ អត់ធ្លាប់សោះ ធ្លាប់តែធ្វើស្រែនឹងដាំបន្លែជាមួយឪពុកហ្នឹង

កៈ អញ្ចឹង?

ខៈ ចាស ញ៉ុមធ្លាប់តែប៉ុនណ្ហឹង

កៈ ចុះអ្នកមីងអ័រ...ដែលធ្វើការងារអត់?

ខៈ អត់ដែលសោះ

កៈ អត់ដែលទេ! បាទហើយពេលអ្នកមីងពេលភាគច្រើនអ្នកមីងថាធ្វើដាំបន្លែចំការមែនទេ?

ខៈ ចាស

កៈ អ្នកមីងដាំអ្វីខ្លះ?

ខៈ ញ៉ុមកាលហ្នឹង ដាំស្ពៃ ដាំត្រសក់ ដាំននោង ដាំអីអញ្ចឹងទៅ

កៈ ហើយពេលអ្នកមីងដាំអ្នកមីងដាំយកទៅលក់ ឬ អ្នកមីងដាំញុំ?

ខៈ កាលហ្នឹងដាំយកទៅលក់

កៈ យកទៅលក់

ខៈ ចាស ហើយញ៉ុមកាលហ្នឹងញ៉ុមអត់មានកង់មានអីជិះទេពេលល្ងាចអញ្ចឹងយើងទៅកាត់បន្លែមកកាត់ទុកនៅត្រឹមផ្ទះព្រឹកឡើងញ៉ុមទូលដើរលក់ហើយ

កៈ ហ្វ!

ខៈ ចាស ទូលមកលក់នៅផ្សារ ខ្ញិតហ្នឹងណាជូនកាលទៅទូលលក់តាមភូមិហ្នឹងអញ្ចឹងទៅកាលហ្នឹង

កៈ អ្នកមីងលក់អញ្ចឹងលក់ពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មានដែល?

ខៈ លក់ពីព្រឹកតាំងពីម៉ោង៧ ដល់ ម៉ោង១១ត្រលប់ទៅផ្ទះវិញហើយ

កៈ មីងចាំទេពេលដែលមីងលក់ហ្នឹងភាគច្រើនបានលុយប៉ុន្មាន?

ខៈ កាលហ្នឹងបាន៥រយ អីដែរ ៥រយ១ពាន់អីច្រើនណាស់

កៈ អញ្ចឹង?

ខ៖ ចាស

ក៖ ហើយអ័រ...១ដុំអ្នកមីងលក់១ដុំប៉ុន្មានកាលហ្នឹង?

ខ៖ កាលហ្នឹងស្ដែមួយគីឡូ ២រយជាងអី

ក៖ ហូ!

ខ៖ ២: ហ្នឹងហើយ

ក៖ ហើយអ្នកមីងយកប៉ុន្មានគីឡូយកទៅលក់?

ខ៖ ញ៉ុមទៅលក់មួយព្រឹកជួនកាលបាន៣គីឡូ ៥គីឡូ គេដាំច្រើនដែលកាលហ្នឹង ចាស ជួនកាលមានម៉ូយទៅកំពុងចាមគេទៅទិញរបស់យើង អញ្ចឹងអាហ្នឹងស្រួលយើងកាត់បោះ ឲគេអស់អស់បាច់ពិបាកដើរលក់ទេ

ក៖ បាទ

ខ៖ ចាស

ក៖ បាទ ហើយដល់ពេលអញ្ចឹងនៅពេលអ្នកមីងលក់បានអញ្ចឹងហើយលុយហ្នឹងអ្នកមីង យកទៅណាអ្នកមីង?

ខ៖ បានទៅម្ដាយញ៉ុមគាត់យកទៅដូចជាទិញម្ហូបអាហារអីអញ្ចឹងទៅណា យើងមានបន្លែ គាត់ទិញម្ហូបហើយទុកលុយហ្នឹងសំរាប់អោយយើងទៅរៀនខ្លះ ទិញសំលៀកបំពាក់ឲយើង ទៅរៀនទិញកង់ទិញអីជិះហ្នឹងណា

ក៖ បាទ អ្នកមីង

ខ៖ ចាស

ក៖ ហើយអ្នកមីងជីវិតពេលអ្នកមីងនៅក្មេងរហូតមកដល់ឥឡូវអ្នកមីងគិតថាខុសគ្នាទេ?

ខ៖ ខុស ញ៉ុមគិតថាកាលពីខ្ញុំនៅជាមួយឪពុកម្ដាយញ៉ុមមានការលំបាកដូចជាធ្វើស្រែ ដាំ បន្លែ ដាំអីដល់ពេលសព្វថ្ងៃ ពេលមានប្ដីមកញ៉ុមអត់សូវលំបាកដូចពេលកាលនៅជាមួយ ឪពុកម្ដាយទេ

ក៖ អ្នកមីងគិតថាឥឡូវអត់សូវធ្វើហើយអត់ពិបាកដូចមុន?

ខ៖ ចាស អត់ពិបាកដូចមុនទេ ដោយសារតែកាលនៅជាមួយឪពុកម្តាយគាត់មានជីវភាព កំសត់ណាស់

ក៖ ហ្នឹងហើយ

ខ៖ ប៉ុន្តែធម្មតាគាត់ចាស់ពីដើមមិនសូវឲយើងសំបូរសប្បាយដូចសព្វថ្ងៃទេណាទោះបីគាត់ មានលុយក៏គាត់មិនឲយើងជាកូនហ្នឹងដូចកូនញ៉ុមសព្វថ្ងៃទេធម្មតាកូនញ៉ុមសព្វថ្ងៃញ៉ុមផ្ត ល់លទ្ធភាពឲគេបានគ្រប់គ្រាន់ ចំនែកកាលពីញ៉ុមនៅជាមួយឪពុកម្តាយញ៉ុមអត់អញ្ចឹងទេ

ក៖ បាទ

ខ៖ ព្រលឹមឡើងគាត់អោយតែញ៉ុមហូបបាយកកទៅរៀន គាត់អត់ដែលមានអោយលុយ ញ៉ុមចាយទេ ដូចកូនញ៉ុមសព្វថ្ងៃចង់បានលុយទៅរៀនបាន ចង់បានលុយទិញអាហារអីផ្សេ ងៗបាន ញ៉ុមអោយពួកគេញុំតែចំនែកឪពុលម្តាយញ៉ុមគាត់អត់ធ្វើអញ្ចឹងទេ

ក៖ ហ្វ!...អ្នកមីង!

ខ៖ ចាស វាខុសគ្នាត្រង់អញ្ចឹងដែរណា តែបើយើងអោយពួកគាត់ដូចជំនាន់យើងវាចូលគេ អត់ចុះទេ មិនអញ្ចឹអ? សម័យហ្នឹងគេវាថាដូចទំនើបដែរហា! វាជឿនលឿនហើយអញ្ចឹង យើងអោយគេធ្វើទៅតាមកាលៈទេសៈដែលសព្វថ្ងៃហ្នឹងទៅ

ក៖ បាទ អ្នកមីងចុះសំរាប់អ្នកមីង អ្នកមីងទាន់សម័យប៉ុលពតទេ?

ខ៖ ញ៉ុមទាន់នៅអាយុ៨ឆ្នាំ

ក៖ ៨ឆ្នាំ?

ខ៖ ចាស កាលសម័យប៉ុលពតញ៉ុមអត់ដែលនៅជាមួយម្តាយទេ ញ៉ុមតូចនៅប៉ុន ហាន់ណា ហ្នឹងមាននាក់មើលផ្សេងហើយឪពុកម្តាយញ៉ុមទៅធ្វើការឆ្ងាយៗ អញ្ចឹងញ៉ុមអត់ដែលបាន ម្តាយណាមកថ្នាក់ថ្នមញ៉ុមទេកាលនៅពីតូចហា! ញ៉ុមនៅជាមួយចាស់ផ្សេង

ក៖ ពេលហ្នឹងគេធ្វើបាបអ្នកមីងច្រើនទេ?

ខ៖ កាលហ្នឹងញ៉ុមអត់ដឹងថាគេធ្វើបាបមិចទេដឹងតាយំរកម្តាយអញ្ចឹង ហើយដឹងបាយទឹកអី ណាទេ អត់ដែលបានបាយទឹកអីញុំអីទេ ដឹងញ៉ុមញុំអីទេកាលហ្នឹង? ចាស តើដែលឃើញ

ម្ដាយញ៉ុមសោះយ៉ូៗទៅញ៉ុមឃើញគាត់ម្ដងយប់ហា! លូចមកជួបកូនអញ្ចឹងទៅដល់ពេលហើយញ៉ុមដេកអញ្ចឹងទៅដឹងខ្លួនឡើងបាត់គាត់ទៀតហើយកាលហ្នឹងហា!

ក៖ ហើយនៅពេលសម័យហ្នឹងអ្នកមីងដឹងថាឪពុកម្ដាយអ្នកមីងធ្វើការអីខ្លះដែលពេលសម័យប៉ុលពត?

ខ៖ សម័យប៉ុលពត?ម្ដាយញ៉ុមគេអោយរែកដីរួចហើយឪពុកញ៉ុមគេអោយឡើងត្នោត អោយទៅធ្វើស្រែអីអញ្ចឹងណាកាលសម័យហ្នឹង

ក៖ ហើយសម័យហ្នឹងអ្នកមីងមានបងប្អូនណាបាត់បង់ទេ?

ខ៖ សម័យប៉ុលពតហា?សម័យប៉ុលពតបាត់ឪពុកមាមួយដែល

ក៖ ហ្វ!

ខ៖ បាត់ទល់សព្វថ្ងៃអត់មានលឺដំណឹងអីសោះ

ក៖ បាទ

ខ៖ ចាស ខាងឪពុកហា ប្អូនពៅរបស់ឪពុកញ៉ុម

ក៖ ហើយអ័រ...ចុះនៅពេលដែលពេលបែកពីសម័យប៉ុលពតវិញអ្នកមីងនៅទីណាវិញ?

ខ៖ ញ៉ុមនៅតែភូមិ អំពិលធំហ្នឹងដដែល

ក៖ អញ្ចឹងហា! ពេលដែលអ្នកមីងនៅក្នុងសម័យប៉ុលពតអ្នកមីងនៅក្នុង ភូមិអំពិលធំហ្នឹងដដែល?

ខ៖ ចាស ពេលសម័យប៉ុលពតអ័រ...ម្ដាយញ៉ុមបាននាំមកនៅក្រោមហ្នឹងណាបានប៉ុន្មានប្រហែលជា១ឆ្នាំដែល ចាសដល់ពេលដាច់ទៅក៏ត្រលប់ទៅស្រុកភូមិវិញ

ក៖ ចុះនៅសម័យប៉ុលពតហ្នឹងគេអត់យកអ្នកមីងពីកន្លែងមួយទៅកន្លែងមួយទេ?

ខ៖ អត់ទេ មាននៅតែជាមួយយាយចាស់មួយនៅតែមួយកន្លែង ចាសដល់ពេលដាច់ទៅម្ដាយទៅយកកូនរៀងៗខ្លួនទៅ

ក៖ អញ្ចឹង នៅពេលដែលនៅសម័យប៉ុលពតហ្នឹងពេលដែលដាច់ហ្នឹងបានន័យថាអ្នកនៅមើលថែរហ្នឹងគេបោះយើងចោល គេរត់យកប្រាស់អាយោសរបស់គេ ឬយ៉ាងមិច?

ខ៖ អត់ទេសម័យប៉ុលពតហ្នឹងដូចជាមានចាស់ម្នាក់អាយុ ៥០ឆ្នាំសំរាប់មើលក្មេងអញ្ចឹងណា! ក្មេង ៣ទៅ៤នាក់គាត់នៅតាមើលថែក្មេងហ្នឹង គាត់អត់មានទៅណាទេមើលទាល់ថាដាច់អាពតអញ្ចឹងម្ដាយទៅយកកូនរៀងៗខ្លួនមកចាស

ក៖ អញ្ចឹងពេលនៅក្មេងមានអ្នកមើលចុះប៉ុន្មានឆ្នាំទើបគេឲធ្វើការ?

ខ៖ កាលហ្នឹងអាយុត្រឹម ១០ឆ្នាំអីគេឲធ្វើការហើយ ចាសគេឲរកចាប់កង្កែប ចាប់ក្ដាមអី គេចាប់ក្ដាមចាប់ខ្យងតាមស្រែកុំឲវាកាត់ស្នូងកាត់អីវាចេះតាប្រើយើងទៅ លើកអាចម៍គោលើកអីអញ្ចឹងទៅណាឲតាធ្វើការកើត

ក៖ ហើយនៅពេលអ័រ...អញ្ចឹងអ្នកមីងសំរាប់អ្នកមីងដែលមានក្ដីស្រមៃអ័រ...ថាអនាគតអ្នកមីចង់ធ្វើអីគេកាលពីអ្នកមីងនៅក្មេង?ដែលមានក្ដីស្រមៃទេ?

ខ៖ ញ៉ុមស្រមៃដែលតាស

ក៖ ស្អីគេទៅ?

ខ៖ កាលហ្នឹងកាលពីខ្ញុំនៅក្មេងៗញ៉ុមនៅរៀនញ៉ុមគិតថាញ៉ុមខំប្រឹងរៀនបានធ្វើគ្រូបង្រៀនកាលហ្នឹងហ! តែអត់បានសោះដោយសារញ៉ុមប្រលង ឌីសប្លូមធ្លាក់កាលហ្នឹងហើយឪពុកម្ដាយញ៉ុមគាត់អត់មានផ្ដល់អីអោយខ្ញុំគ្រប់គ្រាន់សំរាប់រៀនសូត្រហ្នឹងសោះកាលហ្នឹង! ញ៉ុមនឹកឃើញថាពេលហ្នឹងទៅប្រលងគ្រូថាអោយយកលុយមកទិញក្រដាសប្រលងទិញអីគាត់ថាគាត់អត់មានលុយទេ ដូចគាត់អត់សូវជាតស៊ូជាមួយញ៉ុមមិចទេកាលហ្នឹង ហើយញ៉ុមក៏អត់សូវទាមទាគាត់ គាត់ថាអញ្ចឹងញ៉ុមក៏ហីទៅដល់ពេលហើយអត់បានធ្វើអីសោះពេលចប់...ចប់ពីរៀនមកធ្លាក់ឌីសប្លូមមកគាត់ថាកូនអើយកូនស្រីសោះទៅរៀនអីខ្ពស់ម្លេះទេទៅដេរនៅផ្ទះកំប៉ិចកំប៉ុកនឹងទៅអញ្ចឹងក៏អោយញ៉ុមទៅរៀនដេរទៅកាលហ្នឹង

ក៖ ហូ....ដល់ពេលអញ្ចឹងអ្នកមីងក៏ចេះដេរអញ្ចឹងទៅ?

ខ៖ ចាស ហើយដេរបានប៉ុន្មានខែគ្រូនឹងគេទៅពីស្រុកនឹងទៅនៅរកាកោងទៅអីទៅអញ្ចឹងទៅញ៉ុមខានបានរៀនជាមួយគាត់ទៅបានតាតិចតួចហ្នឹងកាលហ្នឹង ចាស

ក៖ ហើយសំរាប់អ្នកមីងអ័រ..អ្នកមីងអត់ដែរមានបទពិសោធន៍ឃ្លានបាយ?

ខ៖ អត់ទេ

កៈ ចុះសំរាប់ភាពល្អវិញអ្នកមីងគិតថាពេលវាលាណាមួយដែលអ្នកមីងគិតថាជាពេលវេលាដែលល្អ មែនទែនម៉ងហា?

ខៈ ដូចអត់ទាន់មានទេ អត់ទាន់មានពេលដែលល្អមែនទែនទេ

កៈ អញ្ជឹងអាល្អធម្មតាវិញ?

ខៈ ចាស មានសព្វថ្ងៃរៀងល្អធម្មតាដូចថាក្នុងគ្រួសារញ៉ុមរស់នៅសព្វថ្ងៃវាមិនសូវមានការលំបាកទេ សូម្បីតែការកស៊ីក៏មិនសូវមានការហាត់នឿយដូចគេដែរ

កៈ បាទ

ខៈ ចាស ចេះតែមានអាហារហូបចុកអីអញ្ជឹងទៅ

កៈ ហើយសំរាប់អ័រអ្នកមីងភាគច្រើនអ្នកមីង  អ្នកមីងចេះធ្វើម្ហូបទេ?

ខៈ ញ៉ុមចេះធ្វើម្ហូប

កៈ អ្នកមីងភាគច្រើនម្ហូបអីគេដែលអ្នកមីងចូលចិត្តជាងគេ?

ខៈ ញ៉ុមចូលចិត្តស្លរកកូរ

កៈ កកូរ?

ខៈ ចាស

កៈ ភាគច្រើនមួយខែកកូរប៉ុន្មានដងដែល?

ខៈ ហ៊ឹម.... មួយខែកកូរពីរដងអី

កៈ ពូអត់ធុញទេ?

ខៈ ពូធុញ ចូលចិត្តស្លរម្ជូរ ពូនឹងកូន

កៈ អញ្ជឹង?

ខៈ ហ្នឹងហើយ

កៈស្លរម្ជូរអីគេដែលអ្នកមីង?

ខ៖ ស្លរម្ហូរធម្មតាហ្នឹងស្លរម្ហូរត្រីស្រែយើងហ្នឹងគាត់ចូលចិត្តកូនអីចូលចិត្តស្លរម្ហូរ

ក៖ បាទ អ្នកមីង

ខ៖ ចាស

ក៖ ហើយសំរាប់អ្នកមីងវិញនៅស្រុកខ្មែរអ្នកមីងដែលដើរទៅខេត្តណាខ្លះ?

ខ៖ ញុំមធ្លាប់ទៅលេងសៀមរាប ទៅលេងខេត្តកំពតអីអញ្ជឹងដែល

ក៖ បាទ

ខ៖ ចាស

ក៖ ទៅជាគ្រួសារ ឬ ម្នាក់ឯង?

ខ៖ ទៅជាលក្ខណះគ្រួសារ

ក៖ អ្នកមីងចូលចិត្តច្រៀងទេ?

ខ៖ ញុំមអត់សូវចូលចិត្តទេ

ក៖ ហេតុអីបានអញ្ជឹង?

ខ៖ ញុំមអត់ចេះ

ក៖ អត់ចេះម៉ង?

ខ៖ ចាស

ក៖ ហើយដល់ពេលអ្នកមីងទំនេរភាគច្រើនអ្នកមីងធ្វើអីគេដែរពេលទំនេរ?

ខ៖ ញុំមនៅផ្ទះអត់សូវទំនេរចេះតែបោះប្រាសដុះជូតលាងបោកខោអាវអីនឹងទៅ ចាសអត់សូវមានពេលទំនេរដែរ

ក៖ បាទ ហើយផ្ទះអ្នកមីងជាប្រភេទអីដែរ?

ខ៖ ជាប្រភេទផ្ទះឈើ

ក៖ ឈើហា?

ខ៖ ចាស

ក៖ ឈើដូចអញ្ចឹង ឬ ក៏ឈើ...?

ខ៖ ឈើដូចអញ្ចឹងប៉ុន្តែរាបថ្មរខាងក្រោម

ក៖ ថ្មរខាងក្រោម ស្អាតត្រជាក់ បាទអ្នកមីងហើយនៅជុំវិញផ្ទះអ្នកមីងមានដើមឈើមានអីទេ?

ខ៖ នៅជុំវិញផ្ទះខ្ញុំដើមច្រើនជាងគេគឺដើមអង្កាញ់

ក៖ ដើមអង្កាញ់

ខ៖ ចាស

ក៖ ត្រជាក់ទេអ្នកមីងអញ្ចឹង?

ខ៖ ត្រជាក់

ក៖ បាទ អ្នកមីងប្រហែលជាថ្ងៃនឹងពួកយើងអត់មានអីទៀតទេមានតែប៉ុណ្ណឹង ហើយថ្លែងអំណរគុណដល់អ្នកមីងខ្លាំងមែនទែនសំរាប់ផ្តល់ឧកាលដើម្បីពួកញ៉ុមបានមកសួរពីជីវប្រវត្តិរបស់អ្នកមីងអញ្ចឹងហាណាហើយថាវាអាចជួយដល់កូនចៅអ្នកមីងអាចបានរៀនច្រើនអំពីអ្នកមីង បាទហើយអញ្ចឹងនៅពេលដែលញ៉ុមបានសម្ភាសន៍នេះចប់ញ៉ុមនឹងដាក់ការសម្ភាសន៍របស់អ្នកមីងនៅក្នុងវេបសាយសាលា BYU ហ្នឹងហា អ្នកមីងអនុញ្ញាតពួកយើងដាក់អត់អ្នកមីង?

ខ៖ បានដែលតាស

ក៖ អញ្ចឹងអគុណច្រើនអ្នកមីងសំរាប់ឧកាសថ្ងៃហ្នឹង

ខ៖ ចាស...ចាស សុខសប្បាយ

ក៖ បាទជំរាបលា!